ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**
លេខ....៩៦...សរ.ផ.ណ../គ.ជ.អ.ប

រាជធានីភ្នំពេញ. ថ្ងៃទី.១៥. ខែ.មី.ណ. ឆ្នាំ២០១១.

**គោរពជូន**

**ឯកឧត្តម លោក លោកស្រី ជាប្រធានក្រុមការងារគ្រប់គ្រង**
**និងអនុវត្តអនុកម្មវិធីនានារបស់ផអ៣**

**<u>កម្មវត្ថុ</u>:** ការបើកគណនីថ្មីសម្រាប់ការអនុវត្តផែនការអនុវត្តរយៈពេល០៣ឆ្នាំ ( ផអ៣ ២០១១-២០១៣) ។

**<u>យោង</u>:** លិខិតលេខ ១១១៨ សហវ-វស ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ស្តីអំពីករណីសំណើសុំបើកគណនីចរន្ត ប្រាក់បញ្ញើជារូបិយប័ណ្ណដុល្លារអាមេរិកនៅធនាគារអេស៊ីលីដា សម្រាប់អនុវត្ត " ផែនការអនុវត្តរយៈពេល ០៣ឆ្នាំនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ " ក្រោមហិរញ្ញប្បទាន ឥតសំណងពីប្រទេសដាណឺមាក់ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ" ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ដើម្បីចាប់ផ្តើមផ្តល់ហិរញ្ញប្បទានសម្រាប់ អនុវត្តសកម្មភាពនានារបស់ផែនការអនុវត្តរយៈពេល៣ឆ្នាំ (ផអ៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សូមឯកឧត្តម លោក លោកស្រីមេត្តារៀបចំចាត់ចែងដើម្បីបើកគណនីថ្មីមួយនៅសាខា ធនាគារអេស៊ីលីដា ដែលមានទីតាំងនៅជិតនឹងក្រសួងរបស់ឯកឧត្តម ។ លេខាធិការដ្ឋានគ.ជ.អ.បបានជួបប្រាស្រ័យ ទាក់ទងជាមួយធនាគារអេស៊ីលីដាភ្នំពេញរួចហើយ ហើយពួកគេបានឯកភាពផ្តល់ការណែនាំដល់សាខារបស់ខ្លួននៅតាម រាជធានីខេត្ត អនុញ្ញាតឱ្យគ.ជ.អ.ប បើកគណនីថ្មីនានា ដោយពុំចាំបាច់តម្រូវអោយមានប្រាក់តម្កល់បើកគណនីឡើយ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោក លោកស្រី មេត្តាចាត់ចែងជួបពិភាក្សាជាមួយសាខាអេស៊ីលីដាដែល នៅជិតក្រសួង ស្ថាប័នដើម្បីបើកគណនីថ្មីដោយមានឈ្មោះគំរូ : NCDD-IP3 (ឈ្មោះក្រសួង-លេខអនុកម្មវិធី ) ។

គណនីធនាគារខាងលើនេះ នឹងត្រូវប្រើប្រាស់សម្រាប់ផ្ទេរមូលនិធិទាំងឡាយដែលបានផ្តល់ដោយដៃគូអភិវឌ្ឍន៍ សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ផអ៣។ បច្ចុប្បន្ន លេខាធិការដ្ឋាន គ.ជ.អ.ប កំពុងរៀបចំអនុស្សរណៈយោគយល់គ្នារវាង គ.ជ.អ.ប នឹងស្ថាប័នអនុវត្តអនុកម្មវិធីនិមួយៗដែលរួមមានតារាងថវិកាលម្អិតសំរាប់ចំណាយក្នុងការអនុវត្តនៃដំណាក់ កាលដំបូងរបស់ផអ៣ ដែលឯកសារនេះនឹងត្រូវបានប្រើប្រាស់សម្រាប់ជាឯកសារយោង និងជាមូលដ្ឋានត្រួតពិនិត្យមុន មានការអនុញ្ញាតចំណាយផ្សេងៗ។ ការអនុវត្តថវិកានេះ នឹងត្រូវមានការត្រួតពិនិត្យជាប្រចាំតាមរយៈការរៀបចំរបាយ ការណ៍ហិរញ្ញវត្ថុ ដោយអនុកម្មវិធីមួយៗ ដែលរបាយការណ៍នេះរួមបញ្ចូលទាំងការវិភាគអំពីស្ថានភាពនៃការប្រើប្រាស់

ថវិកានេះផងដែរ។ អនុសារណៈយោគយល់ ថវិកា និងការណែនាំអំពីការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ នឹងផ្ញើជូនទៅស្ថាប័នអនុវត្តអនុកម្មវិធីទាំង៥ក្នុងពេលឆាប់ៗខាងមុខនេះ ។

ដូច្នេះ ដើម្បីឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប អាចធ្វើការផ្ទេរមូលនិធិដំបូងទៅឱ្យអនុកម្មវិធីទាំង៦បាន លេខាធិការដ្ឋាន គ.ជ.អ.បត្រូវមានព័ត៌មានលម្អិតអំពីគណនីធនាគាររបស់អនុកម្មវិធីនីមួយៗ។ព័ត៌មានទាំងនេះរួមមាន ៖

១. គណនីធនាគារ (លេខ-ឈ្មោះ គណនីធនាគារ និងអាស័យដ្ឋាន)

២. មន្ត្រីមានសិទ្ធិចុះហត្ថលេខា (មន្ត្រីអនុម័តមួយរូប និងមន្ត្រីពិនិត្យបញ្ជាក់មួយរូប)

មន្ត្រីអនុម័តរបស់អនុកម្មវិធីនិមួយៗ គួរធ្វើការតែងតាំងឯកឧត្តម ឬមន្ត្រីណាដែលពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងការអនុវត្តកម្មវិធីជាតិនេះ ហើយគួរធ្វើការតែងតាំងឯកឧត្តម ឬមន្ត្រីណាម្នាក់ផ្សេងទៀតជាមន្ត្រីអនុម័តផ្ទេរសិទ្ធិសំរាប់អនុម័តការចំណាយក្នុងករណីមន្ត្រីអនុម័តអវត្តមាន។ ចំពោះមន្ត្រីពិនិត្យបញ្ជាក់ លេខាធិការដ្ឋានគ.ជ.អ.ប សំណូមពរអោយមានការតែងតាំងឯកឧត្តម ឬមន្ត្រីណាមួយរូបជាមន្ត្រីពិនិត្យបញ្ជាក់ និងមួយ ឬពីររូបផ្សេងទៀតជាមន្ត្រីពិនិត្យបញ្ជាក់ផ្ទេរសិទ្ធិ។ មន្ត្រីពិនិត្យបញ្ជាក់គឺជាមន្ត្រីណាដែលមានការយល់ដឹងដ៏ជ្រាលជ្រៅលើការគ្រប់គ្រងថវិការបស់ ផអ៣ ហើយមន្ត្រីពិនិត្យបញ្ជាក់ផ្ទេរសិទ្ធិក៏អាចបំពេញការងារបានក្នុងករណីអវត្តមានរបស់មន្ត្រីពិនិត្យបញ្ជាក់ ។

នៅពេលដែលអនុកម្មវិធីនិមួយៗ បានធ្វើការតែងតាំងមន្ត្រីនានាដូចបានរៀបរាប់ខាងលើហើយនោះ មន្ត្រីអនុម័តម្នាក់ និងមន្ត្រីពិនិត្យម្នាក់ នឹងត្រូវបំពេញតួនាទីជាមន្ត្រីចុះហត្ថលេខាសំរាប់គណនីធនាគារ។

ជាមួយគ្នានេះដែរ លេខាធិការដ្ឋានគ.ជ.អ.ប ក៏បានទទួលលិខិតអនុញ្ញាតជាផ្លូវការពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការបើកគណនីថ្មីសម្រាប់ផអ៣ ដូចមានជូនភ្ជាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តារៀបចំចាត់ចែង និងផ្ញើមកលេខាធិការដ្ឋាន គ.ជ.អ.ប នូវឈ្មោះគណនីធនាគារ និងមន្ត្រីមានសិទ្ធិចុះហត្ថលេខាឱ្យបានឆាប់ទៅតាមដែលអាចធ្វើទៅបាន។

សូមឯកឧត្តម លោក លោកស្រី មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**ខាំង ចំរើន**